ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ ២០១៥

# ស្តីពី

# លទ្ធផល និងសមិទ្ធិផលសំខាន់ៗ

## ពីការអនុវត្តន៍គម្រោងទាំងឡាយរបស់ *អង្គការខ្មែរដើម្បីការអប់រំ*

## ក្នុងភាពជាដៃគូ

## ជាមួយការិយាល័យអប់រំ យុវជន និងកីឡាស្រុករុក្ខគិរី និងមន្ទីរអប់រំយុវជននិងកីឡា ខេត្តបាត់ដំបង

## និង

## ដោយកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ភូមិ-ឃុំ  និងរដ្ឋបាលស្រុក

## ស្រុករុក្ខគិរី ខេត្តបាត់ដំបង

## I- ឈ្មោះគម្រោងទី១ លើកកម្ពស់សិទ្ធិកុមារ និងការអប់រំកុមារតាមជនបទ

## និដ្ឋភាពរួម

**អង្គការខ្មែរដើម្បីការអប់រំ** (KHEN) បានអនុវត្តការងារផ្នែកវិស័យពីរសំខាន់គឺ៖

១/ផ្នែកលើកកម្ពស់សិទ្ធិកុមារ និងកិច្ចការពារកុមារ, ២/ផ្នែកអប់រំកុមារតាមជនបទ ដែលគម្រោងទាំងពីរនេះអនុវត្តចំនួន៥ឃុំគឺមាន (ឃុំបាសាក់ ឃុំស្តុកបវីក ឃុំព្រែកត្រឡាច ឃុំមុខរា និងឃុំព្រែកជីក) ដែលមាន ១៦ភូមិគឺ (ភូមិអូររំចេក ភូមិអូរតាសេក ភូមិបាសាក់ ភូមិជ្រាំងខ្ពស់ ភូមិឈូក ភូមិប្រឡាយ១៨ ភូមិព្រៃអំពាន់ ភូមិស្រះថត, ភូមិចុងព័រ ភូមិទួលស្វាយ ភូមិព្រះអណ្តូង ភូមិទួលគគី ភូមិកំរ៉ែង ភូមិខ្នាតអំព័រ ភូមិព្រែកជី និងភូមិមួយទៀតគឺស្ថិតនៅចន្លោះនៃក្រុមនីមួយៗ) ក្នុងនោះអនុវត្ត ជាមួយសាលាកម្រងចំនួន៤គឺ (កម្រងចក្រី កម្រងព្រៃអំពាន់ កម្រងទួលគគី និងកម្រងព្រែកជីក) ដែលមានសាលាចំនួន១២សាលារដ្ឋគឺ (ចក្រី ជ្រាំងខ្ពស់ ឈូក, ព្រៃអំពាន់ ប្រឡាយ១៨ ស្រះថត ទួលស្វាយ ព្រះអណ្តូង ទួលគគី អំព័រ ព្រែកជីក និងកំរ៉ែង) និងសាលាសហគមន៍ចំនួន៦គឺ (អូររំចេក អូរតាសេក ជំនាប់ស្សរឃ្លាំង ជំនាប់គគី ចុងព័រ និងពងទឹក) ក្នុងស្រុករុក្ខគិរី ខេត្តបាត់ដំបង។

បច្ចុប្បន្នអង្គការខ្មែរដើម្បីការអប់រំ(KHEN)បានទទួលថវិកាសម្រាប់អនុវត្តគម្រោងឆ្នាំ២០១៥នេះ ដោយមានការសហការឧបត្ថម្ភពី អង្គការEDUCO ពីប្រទេសអេស្ប៉ាញ (ដោយមានបដិភាគពីសហគមន៍) និងបន្តគម្រោងដដែលនេះសម្រាប់ឆ្នាំ២០១៦ខាងមុខ។

## លទ្ធផលសម្រេចបាន

- **សកម្មភាពទី១: យុទ្ធនាការប្រមូលសិស្សចូលរៀន៖**
  សហការជាមួយនាយក គ្រូបង្រៀន និងគណកម្មការទ្រទ្រង់សាលា អាជ្ញាធរមូលដ្ឋាននិងសិស្សានុសិស្ស រៀបចំក្បួនដង្ហែយុទ្ធនាការប្រមូលសិស្សចូលរៀនក្នុង១២សាលារដ្ឋ និង៦សាលាសហគមន៍ ក្នុងនោះបានជម្រុញការលើកទឹកចិត្តមាតាបិតា អោយបញ្ជូនកូនមកចុះឈ្មោះក្នុងសាលាបឋមសិក្សាសហគមន៍ និងក្នុងមត្តេយ្យរដ្ឋ និងសាលាបឋមសិក្សារដ្ឋ។

- **សកម្មភាពទី២: ដំណើរការថ្នាក់រៀន និងធ្វើកិច្ចសន្យាគ្រូសហគមន៍៖**
  - ចូលរួមកម្មវិធីបើកបវេសនកាលឆ្នាំសិក្សា២០១៥-២០១៦ នៅតាមសាលា កម្រងទាំង៤។
  - រៀបចំដំណើរការថ្នាក់រៀនចំនួន៦សាលាសហគមន៍ ដែលមានសិស្សសរុប ៩៥៦ស្រី ៤៥៣នាក់ បានបន្តនិងចូលរៀន។
  - ផ្តល់ការឧបត្ថម្ភប្រាក់ខែគ្រូសហគមន៍៣នាក់ ក្នុងមួយនាក់ថវិកា$៥០.០០ក្នុង១ខែ និងឧបត្ថម្ភថ្លៃសាំងសម្រាប់គ្រូរដ្ឋដែលមានផ្ទះនៅឆ្ងាយពីសាលាចំនួន៧នាក់ក្នុងមួយនាក់ទទួលបាន $២០.០០ ក្នុង១ខែពេញ១ឆ្នាំសិក្សា ២០១៤-២០១៥។

- ដំណើរការនិងផ្តល់សម្ភារៈតុបតែងថ្នាក់កម្មវិធីសាលាកុមារមេត្រី១ឈុត និងសម្ភារៈឧបទេសសំរាប់ផលិត ក្នុងការរៀន និងបង្រៀន១ឈុត (មានៈ ក្រដាស់កាតុង ក្រដាស់រាមធំ ក្រដាស់ពណ៌ គូល័រ ហ្វឺត កន្ត្រៃ កាវ ហិបដែក តារាទាំង៩ និងសម្ភារៈផ្សេងៗទៀត និងសម្ភារៈសម្រាប់ផលិតគាំទ្រដល់ការរៀននិងបង្រៀន) ដល់១២សាលារដ្ឋ និង៦សាលាសហគមន៍ ក្នុងការរៀបចំ និងតាក់តែងថ្នាក់រៀនដល់សិស្សចូលចិត្ត និងមានការទាក់ទាញដល់ការសិក្សារបស់សិស្ស។

- កំណត់ និងចងក្រងបញ្ជីឈ្មោះកុមារគោលដៅ ៦សាលាសហគមន៍ និង១២សាលារដ្ឋ សរុបបានចំនួន ១១៩៤នាក់ ក្នុងសាលាសហគមន៍ទាំង៦។

- **សកម្មភាពទី៣: គាំទ្រ និងដំណើការបណ្ណាល័យជ្រុងសម្រាប់សាលារដ្ឋនិងសាលាសហគមន៍៖**
  - ដំណើរការនិងផ្តល់នូវសម្ភារៈបណ្ណាល័យជ្រុងដល់ ១៨សាលារៀន ហើយផ្តល់នៅសៀវភៅរឿង សៀវភៅផាត់ពណ៌ ក្រដាស់កាតុង ក្រដាស់រាមធំ ក្រដាស់ពណ៌ គូល័រ ហ្វឺត កន្ត្រៃ កាវ ហិបដែក និងសម្ភារៈផ្សេងៗទៀត សម្រាប់សកម្មភាពបណ្ណាល័យសិស្ស និងបណ្ណារក្ស។

  - ពង្រឹងសេវាបណ្ណាល័យសម្រាប់កុមារនៅតាមសាលា គោលដៅទាំង១៨។

- **សកម្មភាពទី៤: ការធ្វើផែនការអង្គការ និងអ្នកពាក់ព័ន្ធជាមួយគម្រោង៖**
  - រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីគម្រោងកម្មវិធីបន្តសម្រាប់ឆ្នាំ២០១៦ ជាមួយអង្គការដៃគូរទាំងអស់ដែលកំពុងធ្វើការក្នុងស្រុករុក្ខគិរី ស្តីពីការឆ្លុះបញ្ចាំងសកម្មភាពប្រចាំឆ្នាំ២០១៥ បាលចំនួន១លើក នៅសាលប្រជុំសាលាស្រុករុក្ខគិរី ដោយបង្ហាញពីលទ្ធផលការងារ១ឆ្នាំរបស់អង្គការ និងកិច្ចសហការពីអាជ្ញាធរ និងពិភាក្សាពីបញ្ហាប្រឈម និងផែនការសកម្មភាពបន្តសម្រាប់ឆ្នាំ២០១៦។

- **សកម្មភាពទី៥: បណ្តុះបណ្តាលគណៈកម្មការទ្រទ្រង់សាលា៖**
  - គណៈកម្មការទ្រទ្រង់សាលាៈ មាន១៨ក្រុម ក្នុង១៨សាលា ៩០ នាក់ (ស្រី៣៦)

  - សម្របសម្រួលប្រជុំគណៈកម្មការទ្រទ្រង់សាលា នៅក្នុងសាលាគោលដៅទាំង១៨ បានចំនួន ៤៨ដង ក្នុងការងារស្វែងរកធនធានសាងសង់ និងជួសជុលសាលា និងថែរក្សាសាលារៀន និងរៀបចំកិច្ចការងារផែនការអភិវឌ្ឍន៍។

  - សម្របសម្រួលប្រជុំពិភាក្សារវាងអាណាព្យាបាល គណៈកម្មការទ្រទ្រង់សាលា និងតំណាងសាលារៀន និងគ្រូ លើដំណើរការរៀន បង្រៀន និងការជួយពីសហគមន៍ បាន១៨ដង/១ឆ្នាំ ក្នុង១៨សាលាគោលដៅ។

- **សកម្មភាពទី៦: បណ្តុះបណ្តាលពង្រឹងសមត្ថភាពមាតាបិតាគំរូ និងជនបង្គោលកិច្ចការពារកុមារ៖**

- ជនបង្គោលកិច្ចការពារកុមារមានចំនួន ៤៨ នាក់ (ស្រី២) ក្នុង១៨សាលានិងភូមិ។ ជនបង្គោលបានទទួលចំណេះដឹងពីកិច្ចការពារកុមារ និងវិធីសាស្ត្រផ្សព្វផ្សាយបន្ត និងមានបដា និងផ្ទាំងប៉ាណូសម្រាប់បង្ហាញ និងសៀវភៅផ្ទាត់ពណ៌មានរូបភាពណែនាំ និងពន្យល់ និងមានប្រព័ន្ធបញ្ជូននិងលេខទូរស័ព្ទបន្ទាន់សម្រាប់រាយការណ៍ និងបានរៀបចំយុទ្ធសាស្ត្រកាត់បន្ថយហានិភ័យតាមសហគមន៍ ជាពិសេសតំបន់មាត់ទឹកនិងភ្នំ និងទីកន្លែងស្ងាត់ ជាពិសេសការការពារសុវត្ថិភាពកុមារ ពេលមកសាលារៀន ដូចជាការអោយគាត់ដើរជាក្រុមជាដើម។

- វគ្គបណ្តុះបណ្តាល ដល់ជនបង្គោលភូមិ ឃុំ ស្រុក គ្រូបង្រៀន នាយកសាលា ស្តីពីកិច្ចការពារកុមារ និងសិទ្ធិកុមារ ចំនួន១ដង ដើម្បីចូលរួមលើកកម្ពស់ពីបរិយាកាសជុំវិញកុមារមេត្រី និងមិនមានអំពើហិង្សាលើកុមារនិងជនងាយរងគ្រោះ និងផងដែលជនបង្គោលផ្សព្វផ្សាយបន្តដល់សហគមន៍ សិស្ស និងប្រជាពលរដ្ឋ។

- សម្របសម្រួលផ្តល់វគ្គសិក្ខាសាលាស្តីពី **ផលប៉ះពាល់នៃការប្រើអំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារការរំលោភបំពានលើកុមារ** ដល់គ្រួសារប្រឈម, អាជ្ញាធរភូមិនិងឃុំ ចំនួន៩០ គ្រួសារ ដែលមកពីភូមិគោលដៅចំនួន១៦ ក្នុងស្រុករុក្ខគិរី ចំនួន០២ថ្ងៃ និងបានជួយដល់ការយល់ដឹង និងកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសាលារៀនគ្មានអំពើហិង្សា និងមានបណ្តាញជួយអន្តរាគមន៍បន្ទាន់សម្រាប់ពេលមានករណីសង្ស័យណាមួយកើតមាន ឬអាចកើតឡើងចំពោះកុមារ និងជនងាយរងគ្រោះ។

- សម្របសម្រួលប្រជុំជាមួយគ្រួសារមាននិងរងអំពើហឹង្សាបានចំនួន ១៨ដង (តាមសាលារៀន) និងផ្សព្វផ្សាយពីការយល់ដឹងនិងចូលរួមកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់ដល់កុមារ។

- ការចុះផ្សព្វផ្សាយពីសិទ្ធិកុមារ និងកិច្ចការពារកុមារដល់ជនបង្គោលៈ ធ្វើជារៀងរាល់ខែ បានចំនួន ៤៣ ដង នៅក្នុងភូមិគោលដៅទាំង១៦ទីតាំង។

- **សកម្មភាពទី៧: វគ្គបំប៉ន គ្រូបង្រៀនតាមសាលាបឋមសិក្សា និងគ្រូតាមសាលាសហគមន៍ស្តីពី៖**
  - សហការជាមួយមន្ទីរអប់រំ និងការិយាល័យអប់រំស្រុក បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀន ស្តីពី **គោលវិធីសិស្ស មជ្ឈមណ្ឌល និងកម្មវិធីសាលាកុមារមេត្រី និងបំណិន** ចំនួន១លើក ដល់គ្រូបង្រៀនគោលដៅចំនួន៩៦នាក់។

  - គាំទ្រការប្រជុំបច្ចេកទេសគ្រូ ជាមួយប្រធានការិយាល័យអយកស្រុករុក្ខគិរី នៅតាមសាលាកម្រងទាំង៤ (កម្រងចក្រី, កម្រងព្រៃអំពាន់, កម្រងទួលគគី និងកម្រងព្រែកជីក) នៅរៀងរាល់ថ្ងៃព្រហស្បតិ៍ ចុងខែ បានចំនួន១០លើក ពីវិធីសាស្ត្រ និងបច្ចេកទេសបង្រៀន។

- **សកម្មភាពទី៨: បង្កើនទំនាក់ទំនងជាមួយបណ្តាញការងារ៖**

- បង្កើនទំនាក់ទំនងជាមួយបណ្តាញការងារឃុំ និងភូមិដើម្បីធ្វើចលនារកធនធានចូលរួមក្នុងការសាងសង់សាលា សួន បង្គន់អនាម័យតាមសាលាបឋមសិក្សា និងសាលាសហគមន៍ ចំនួន១៨សាលាគោលដៅក្នុង ឃុំបាសាក់, ឃុំស្តុកបវឹក, ឃុំព្រៃកគ្រឡាច, ឃុំមុខរា និងឃុំព្រៃកជីក ។

- ចូលរួមប្រជុំជាមួយ គណៈកម្មការពិគ្រោះយោបល់ស្ត្រីនិងកុមារថ្នាក់ស្រុក (គ.ក.ស.ក) ជាប្រចាំខែ នៅសាលប្រជុំសាលាស្រុកបានចំនួន១២ដង/ឆ្នាំនិងរាយការណ៍ពីករណីដែលខេនបានចូលរួមអន្តរាគមន៍។

- **សកម្មភាពទី៩: ពង្រឹងសមត្ថភាពប្រធានក្រុមក្លឹបកុមារ ក្រុមប្រឹក្សាកុមារ និងសមាជិកក្រុម ៖**
  - ក្រុមក្លឹបកុមារមាន១៨ក្រុមក្នុង១៨សាលាគោលដៅប្រធានក្រុម ក្លឹបកុមារ សរុប៩០នាក់ (ស្រី ៥២នាក់) ដោយបានទទួលការបណ្តុះបណ្តាលពីវិធីសាស្រ្តផ្សព្វផ្សាយ និងអំពីសិទ្ធិកុមារ និងប្រធានបទបំណិនជីវិតផ្សេងៗដូចជា ការជៀសវាងពីអំពើហិង្សា ការប្រើប្រាស់គ្រឿងស្រវឹងឬញៀន ការថែរក្សាសុខភាពអនាម័យ។ល។ និងក្រុមបានផ្សព្វផ្សាយចែករំលែកចំណេះដឹងដល់កុមារដទៃរួមទាំងសហគមន៍ផងដែរ។

  - សម្របសម្រួលដំណើរការប្រជុំក្រុមក្លឹបកុមារស្តីពីការយល់ដឹងអំពីបំណិនជីវិតដូចជា សិទ្ធិនិងការទទួលខុសត្រូវ សិទ្ធិកុមារពិការនិងការចូលរៀនរបស់កុមារពិការ វិធីការពារជង្គូវព្រូន និងខ្លឹមសារច្បាប់ទប់ស្កាត់អំពើហឹង្សា បានចំនួន ៧៧ដង ក្នុង១៨សាលាគោលដៅ។ ដោយបានបញ្ជ្រាបពីការយល់ដឹងពីសិទ្ធិ និងការទំនួលខុសត្រូវរបស់កុមារ និងមនុស្សធំ និងរដ្ឋ និងប្រធានបទបំណិនជីវិតងាយៗដូចជាសុខភាពអនាម័យ កម្មវិធីជង្គូវព្រូន និងកិច្ចការពារខ្លួន ព្រមទាំងបានអនុវត្តវិធីសាស្រ្តផ្សព្វផ្សាយបន្ត អនុវត្តផ្ទាល់ តាមក្រុមពិភក្សា និងរៀបចំផែន ការប្រជុំជាមួយសមាជិកក្លឹបឬក្រុមប្រឹក្សាកុមារបន្ត ដោយមានការគាំទ្រពីអ្នកស្ម័គ្រចិត្តគម្រោង។

  - បានរៀបចំទិវាកុមារអន្តរជាតិខួបលើកទី៦៦ តាមសាលាគោលដៅទាំង១៨សាលារៀននិងសាលាសហគមន៍ បាន១៨ដង ក្នុងកម្រងចក្រី, កម្រងព្រៃអំពាន់, កម្រងទួលគគី និងកម្រងព្រៃកជីក។

- **សកម្មភាពទី១០: វេទិការសាធារណៈស្តីពី សិទ្ធិកុមារ និងដំណោះស្រាយបញ្ហាកុមារ**
  - បានសហការជាមួយឃុំ និងការិយាល័យអប់រំស្រុករៀបចំវេទិការ **យុទ្ធនាការសកល ស្តីពីសិទ្ធិទទួលបានការអប់រំ និងកាតព្វកិច្ចរបស់យើងទាំងអស់គ្នា** បាន១លើក នៅសាលាបឋមសិក្សាជំនាប់គគីរ ដោយបង្កើនការយល់ដឹងពីកាតព្វកិច្ចរបស់រដ្ឋ និងមាតាបិតា សហគមន៍ ក្នុងការជម្រុញ និងអនុវត្តការធានាបានថាកុមារគ្រប់រូបទទួលបានការអប់រំ និងប្រកបដោយគុណភាព។

  - សម្របសម្រួលកម្មវិធី**វេទិកាសវនកម្មសង្គមស្តីពីបរិស្ថានសាលារៀនល្អនៅកំរិតសាលាបឋមសិក្សា** បានចំនួន២លើកមានអ្នកចូលរួមសរុប ១៦៦នាក់ (ស្រី១១០) នៅសាលាបឋមសិក្សាព្រៃកជីកនិងចក្រីដោយជម្រុញការចូលរួមពីអ្នកផ្តល់សេវា (សាលារដ្ឋ និងសាលាសហគមន៍) ដោយឆ្លើយតបពីតម្រូវការ

សម្រាប់ការសិក្សារបស់កុមារ និងជជែកពិភាក្សា និងដំណោះស្រាយនូវតម្រូវការដែលមាតាបិតា និងសហគមន៍បានលើកឡើង ដោយផ្ទាល់ៗនិងត្រង់ៗនឹងគ្នា និងមានផែនការដោះស្រាយរួមគ្នានិងមិនទំលាក់កំហុសដាក់គ្នា។ ដោយមានវាគ្មិនចូលរួមបកស្រាយសំណួររបស់ប្រជាពលរដ្ឋ និងកុមារពីបញ្ហាទាក់ទិន និងការអនុវត្តិកាតព្វកិច្ច ឆ្លើយតបចំពោះការជម្រុញការសិក្សារបស់កុមារគ្រប់គ្នា កង្វះគ្រូបង្រៀន និងបញ្ហាម៉ោងសិក្សាមិនគ្រប់ កែលម្អជាសាលាកុមារមេត្រី ការប្រើអំពើហិង្សាលើកុមារ និងពលកម្មកុមារ និងស្វែងរកថវិកាបដិភាគពីឃុំ ឬស្រុកក្នុងការជួយដល់វិស័យអប់រំ និងសុខមាលភាពសង្គម ជាពិសេសសាលាបឋមសិក្សាសហគមន៍។

- **សកម្មភាពទី១១: គាំទ្របញ្ជូនកុមារងាយរងគ្រោះថ្នាក់ដល់អាយុជីវិតរកសេវាព្យាបាលនិងសង្គ្រោះ**
  - សម្របសម្រួលបញ្ជូន និងអន្តរាគមន៍កុមាររងគ្រោះថ្នាក់ បាន០២ ករណី(ធ្ងន់ធ្ងរ)។

- **សកម្មភាពទី១៣:ការកែលម្អ និងជួសជុលសាលារដ្ឋ និងសហគមន៍ចំនួន១៨អោយក្លាយជាសាលាកុមារមេត្រី**
  - សហការជាមួយនាយកសាលា គណកម្មការទ្រទ្រង់សាលា អាជ្ញាធរ និងសហគមន៍ បានសាងសង់សាលាបឋមសិក្សាសហគមន៍បាន៦ខ្នងធ្វើពីឈើ បង្គន់អនាម័យស្រី ប្រុស ចំនួន៦កន្លែងតាមសាលាសហគមន៍ក្នុង និងដាក់ទោងសិស្សលេង ទ-ទឹក លូដុតសំរាម កន្លែងលាងដៃ ទីធ្លាសាលាចាក់សាបផ្លូវចូលសាលា ដាក់ពាងធំ និងរៀបចំដាំសួនសម្រាប់កុមារលេងតាមតំបន់ជួបការលំបាក ដែលមានរាយនាមខាងក្រោមៈ

១. សាលាអូរតាសេកៈ សាងសង់អាគារសាលារៀនបាន១ខ្នងមាន៣បន្ទប់ ដាក់ទោងចំនួន២ ពាងទឹក២ ទ-ទឹក១ សាងសងបង្គន់ ២បន្ទប់ (ប្រុស-ស្រី) ឡដុតសំរាម១ ធ្វើសួន និងទីធ្លាសម្រាប់លេងកំសាន្តរបស់កុមារ និងទីជម្រកពីកំដៅ។

២. សាលាអូររំចេកៈ សាងសង់អាគារសាលារៀនបាន១ខ្នងមាន២បន្ទប់ ដាក់ទោងចំនួន២ ពាងទឹក២ ទ-ទឹក១ សាងសងបង្គន់ ១បន្ទប់ ឡដុតសំរាម១ ធ្វើសួន និងទីធ្លាសម្រាប់លេងកំសាន្តរបស់កុមារ និងទីជម្រកពីកំដៅ។

៣. សាលាជំនាប់គគីរៈ សាងសង់អាគារសាលារៀនបាន១ខ្នងមាន៣បន្ទប់ ដាក់ទោងចំនួន២ ពាងទឹក២ ទ-ទឹក១ សាងសងបង្គន់ ២បន្ទប់ ឡដុតសំរាម១ ធ្វើសួន និងទីធ្លាសម្រាប់លេង។

៤. សាលាជំនាប់ស្បូវភ្លាំងៈ សាងសង់អាគារសាលារៀនបាន១ខ្នងមាន៣បន្ទប់ ដាក់ទោងចំនួន២ ពាងទឹក២ ទ-ទឹក១ សាងសងបង្គន់ ២បន្ទប់ ឡដុតសំរាម១ ធ្វើសួន និងទីធ្លាសម្រាប់លេង។

៥. សាលាពងទឹកៈ បានរៀបចំធ្វើសួន ដាក់ទោង២ ពាងទឹក២ ទ-ទឹក១ និងទីធ្លាសម្រាប់លេង និងដងទង់ជាតិ (ដោយបន្ថែមលើសាលាដែលត្រូវបានសាងសង់ដោយសហគមន៍មុនគម្រោងចាប់ផ្តើម)។

៦. សាលាចុងពរៈ សាងសង់អាគារសាលារៀនបាន១ខ្នងមាន២បន្ទប់ ដាក់ទោងចំនួន២ ពាងទឹក២ ទ-ទឹក១ សាងសង់បង្គន់២បន្ទប់ ឡដុតសំរាម ធ្វើសួននិងទីធ្លាសម្រាប់លេង។

**<u>បញ្ជាក់:</u>** ក្នុងចំណោមសាលាទាំង៦ ការិយាល័យអប់រំយុវជន និងកីឡាស្រុករុក្ខគិរី បានឯកភាព និងទទួលស្គាល់សាលាសហគមន៍របស់ខេនចំនួន៥ ជាសាលារដ្ឋ។

- សាងសង់បន្ថែម និងជួសជុលបង្គន់អនាម័យនៅសាលារដ្ឋបានចំនួន៥ខ្នង ដូចខាងក្រោមៈ

១. សាលាបឋមសិក្សា ខ្នាចអំពរ
២. សាលាបឋមសិក្សា ទួលស្វាយ
៣. សាលាបឋមសិក្សា ចក្រី
៤. សាលាបឋមសិក្សា ព្រៃអំពាន់
៥. សាលាបឋមសិក្សា ស្រះថត

## I- ឈ្មោះគម្រោងទី២ ធានាបានការអនុវត្តការអប់រំការបញ្ចូលគ្នាសម្រាប់កុមារពិការ

### ទិដ្ឋភាពរួម

គម្រោងនេះបានអនុវត្តន៍បាននឹងកំពុងអនុវត្តការងារក្នុងវិស័យសំខាន់ៗដូចជា ការលើកកម្ពស់សិទ្ធិកុមារ កិច្ចការពារកុមារ និងការអប់រំបញ្ចូលគ្នា សម្រាប់កុមារនៅតាមសាលាបឋមសិក្សាដែលជួបការលំបាកគម្រោងនេះអនុវត្តក្នុងស្រុករុក្ខគិរី ខេត្តបាត់ដំបងក្នុងនោះអនុវត្តជាមួយសាលាបឋមសិក្សាសហគមន៍ចំនួន៦ និងសាលារដ្ឋចំនួន៤ សរុបចំនួន១០សាលាគោលដៅ។

| | |
|---|---|
| រយៈពេលគម្រោង: | ២ឆ្នាំ (ចាប់ពីខែមករា ២០១៥ ដល់ ធ្នូ ២០១៦) |
| ម្ចាស់មូលនីធិ: | ជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលីតាមអង្គការយូនីសេហ្វ<br>(Australian Aid through Unicef ) |
| អនុវត្តគម្រោងដោយ: | អង្គការខ្មែរដើម្បីការអប់រំ (KHEN) *(ដោយមានបដិភាគពីសហគមន៍)* |
| តំបន់គោលដៅ: | សាលាបឋមសិក្សា ១០សាលា (សាលាបឋមសិក្សារដ្ឋ ៤ និងសាលាសហគមន៍ ៦) |

### លទ្ធផលសំរេចបាន

- **<u>សកម្មភាពសម្របសម្រួលជួសជុល និងសាងសងសាលារៀន និងបរិស្ថានសាលា និងបន្ថែមជំរាលសម្រាប់សិស្សពិការក្នុងការអប់រំបញ្ចូលគ្នា</u>**

  បានសម្របសម្រួលសាងសង់ជំរាលសម្រាប់កុមារពិការ ដើម្បីងាយស្រួលអោយកុមារចេញចូលថ្នាក់រៀន និងបន្ទប់ទឹក ក្នុង៨សាលាដូចខាងក្រោម:

| | |
|---|---|
| ១. សាលាបឋមសិក្សាទួលគគីរ | ២. សាលាបឋមសិក្សាជំនាប់គគីរ |
| ៣. សាលាបឋមសិក្សាជំនាប់ស្បូវភ្លាំង | ៤. សាលាបឋមសិក្សាចុងពរ |
| ៥. សាលាបឋមសិក្សាអូរតាសេក | ៦. សាលាបឋមសិក្សាអូររំចេក |
| ៧.សាលាបឋមសិក្សាពងទឹក | ៨. សាលាបឋមសិក្សាព្រៃកដីក |

- **<u>សកម្មភាពគាំទ្រ សិទ្ធិកុមារពិការ កិច្ចការពារកុមារ និងការអប់រំបញ្ចូលគ្នា</u>**
  - សម្របសម្រួលបញ្ជូន និងអន្តរាគមន៍កុមាររងគ្រោះ បាន៥ ករណី ក្នុងនោះកុមារពិការសរុបចំនួន ០៥នាក់ (ស្រី២) ដែលមានប្រភេទពិការថ្លង់២នាក់ ភ្នែក ១នាក់ និង សតិអារម្មណ៍ ២នាក់ បានទទួលសេវាព្យាបាល និងអាចស្តាប់បានខ្លះៗ និងមានភាពប្រសើរជាងមុន

- សិក្សា ប្រមូល និង ចងក្រងទិន្នន័យ ជា ឯកសារ ដែលមានសិស្សសរុប ២៧៩២នាក់ ស្រី១៣៥២ ក្នុងនោះ កុមារពិការសុរប៧០នាក់ ស្រី២៩នៅក្នុង១០សាលា និង១០ភូមិ។

- សម្របសម្រួល ចុះសិក្សាពត៌មានដើមគម្រោង និងគូរផែទីសាលា នៅក្នុងសាលាគោលដៅទាំងអស់ ១៨សាលា។

- សម្របសម្រួលយុទ្ធនាការចុះឈ្មោះចូលរៀន នៅក្នុងសាលាគោលដៅទាំង១០គោលដៅ ដោយមានសិស្សចូលរួម និងជនពិការផងដែរ។

- ចូលរួមកម្មវិធីបើកបវេនកាលឆ្នាំសិក្សា២០១៥-២០១៦ នៅតាមសាលាគោលដៅចំនួន៤សាលា។

- សម្របសម្រួលប្រជុំ អាណាព្យាបាលល្អ (គំរូ) បានចំនួន៧ដង នៅក្នុង ៦សាលាគោលដៅ ដែលមានអ្នកចូលរួមសរុប ១៥៧នាក់ (ស្រី៩២) ពិការ ១៧នាក់(ស្រី២) និងស្វែងយល់ការថែទាំកុមារពិការ និងការស្វែងរកសេវាជំនួយនានា ការផ្តល់គុណតម្លៃដល់ការសិក្សារបស់កុមារពិការ។

- ផ្សព្វផ្សាយការយល់ដឹង បន្ថែមទាក់ទងនឹងសិទ្ធិជនពិការ ទស្សនៈទាន និងការកាត់បន្ថយការរើសអើង និងមិនបានមើលឃើញពីសមត្ថភាពជនពិការឬកុមារពិការ និងការអប់រំបញ្ចូលគ្នា ទៅដល់គ្រូ នាយកសាលា និងគណៈកម្មការទ្រទ្រង់សាលា និងអាជ្ញាធរភូមិឃុំ ចំនួន ២ដង នៅក្នុងវត្តសិក្ខាសាលា ដែលមានអ្នកចូលរួម សរុប ១០៦នាក់ (ស្រី ៤៧)។

- ចុះសិក្សា និងទស្សនៈកិច្ចតាមផ្ទះទៅលើកុមារពិការគោលដៅបាន១០សាលា ដោយបានជម្រុញអោយកុមារបានចូលរៀន និងមានគ្រូជួយបង្រៀនតាមសាលានិងតាមផ្ទះដោយបងប្អូន។

| | |
|---|---|
| ១. សាលាចុងពរ | បាន ៥នាក់ ស្រី ៤ |
| ២. សាលាព្រៃអំពាន់ | បាន ៣នាក់ ស្រី ០នាក់ |
| ៣. សាលាព្រែកជីក | បាន ២០នាក់ ស្រី ៤នាក់ |
| ៤. សាលាទួលគគី | បាន ៨នាក់ ស្រី ៣នាក់ |
| ៥.សាលាអូរតាសេក | បាន ១៣នាក់ ស្រី ៣ |
| ៦. សាលាពងទឹក | បាន ៣នាក់ ស្រី០ |
| ៧. សាលាជំនាប់គគីរ | បាន ៨នាក់ ស្រី៤ |
| ៨. សាលាជំនាប់ស្បូវភ្លាំង | បាន ៤នាក់ ស្រី២ |
| ៩. សាលាអូររំចេក | បាន១២នាក់ ស្រី៧ |
| ១០. សាលាចក្រី | បាន១៣នាក់ ស្រី២ |

- ផ្សព្វផ្សាយលើកកម្ពស់សិទ្ធិជនពិការ សមត្ថភាពជនពិការ និងតម្រូវការរបស់ជនពិការ និង សហគមន៍មេត្រីភាព២៣ដង នៅក្នុងសាលាគោលដៅទាំង១០ របស់គម្រោង អ្នកចូលរួម សរុបៈ៥៥២ នាក់ ស្រី២២១ នាក់។

- **<u>សកម្មភាពវគ្គបំប៉នសិក្ខាសាលា និង វគ្គបណ្តុះបណ្តាលការយល់ដឹងនិងលើកកម្ពស់សិទ្ធិជនពិការ</u>**

  បុគ្គលិករុក្ខគិរីចំនួន ៨នាក់ ស្រី៤ក្នុងនោះអ្នកសម្របសម្រួលគម្រោង ១នាក់ (ស្រី០) បុគ្គលិកគម្រោង ៣ នាក់ (ស្រី១) និង បុគ្គលិករៀនសូត្រ ៤នាក់ (ស្រី៣) បានចូលរួម វគ្គបណ្តុះបណ្តាល នៅថ្ងៃទី២៣ និង២៤ ខែមិនា ឆ្នាំ២០១៥ ស្តីពីច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ និងបានបន្តការបំប៉នដល់សហគមន៍និងជនបង្គោលមានសរុប១០គោលដៅ ផ្សព្វផ្សាយបន្ត និងដល់ក្លឹបកុមារក្នុងការទទួលស្គាល់និងការលេងជាមួយកុមារពិការដោយកាត់បន្ថយការ រើសអើង។

- **<u>ការជួយផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូជំនួយបង្រៀនកុមារពិការក្នុងថ្នាក់ឬសាលា</u>**

  **អង្គការខ្មែរដើម្បីការអប់រំ** បានផ្តល់ការគាំទ្រប្រាក់ឧបត្ថម្ភថ្លៃសាំងសម្រាប់គ្រូបង្គោលជួយបង្រៀន និងថែទាំកុមារពិការចំនួន១០នាក់ នៅក្នុងសាលាគោលដៅរបស់គម្រោងទាំង១០ ដោយគ្រូបានចំណាយពេលបន្ថែមលើការមើលការថែទាំនិងបង្ហាត់កុមារតាមថ្នាក់ ម្នាក់ចំនួន២០ដុល្លា/មួយខែ។

- **<u>ការចងក្រងក្រុមជួយដល់កុមារពិការ</u>**

  គ្រូបង្គោលគាំទ្រកុមារពិការ ១០ នាក់ (ស្រី៤) ក្នុង ១៨សាលា គណៈកម្មការពិការភាព មាន ១០ ក្រុម ក្នុងភូមិគោលដៅចំនួន ១០ មានសមាជិកសរុបៈ ៥០នាក់ (ស្រី១៩)។

## II- ឈ្មោះគម្រោងទី ៣ កម្មវិធីសវនកម្មសង្គម

រយៈពេលគម្រោងសាកល្បងៈ៣ខែ (ចាប់ពីខែកញ្ញា ដល់វិច្ឆិកា ២០១៥)

គាំទ្រថវិកាដោយៈ អង្គការ NEP (កញ្ចប់ថវិកាខ្នាតតូច)

អនុវត្តគម្រោងដោយៈ អង្គការខ្មែរដើម្បីការអប់រំ (KHEN)

តំបន់គោលដៅៈ ២សាលារៀនគោលដៅ សាលាបឋមសិក្សាព្រែកជីក និងចក្រី ស្រុករុក្ខគិរី ខេត្តបាត់ដំបង

**<u>លទ្ធផលសម្រេចបាន</u>**

សវសនកម្មសង្គមជាកម្មវិធីរៀបចំជាវេទិកាសាធារណៈដដែកស្មើភាពគ្នារវាងអ្នកទទួលបានសេវាពីរដ្ឋ និង អ្នកទទួលបានសេវាជាពិសេសកុមារ និងរៀបចំផែនការជាក់លាក់តាមកិច្ចសន្យាដែលបានឯកភាព និង លើកឡើងក្នុងពេលពិភាក្សាសវនកម្មសង្គម លើប្រធានបទដែលគម្រោបបានសហការរៀបចំវេទិកាស្តីពីៈ **បរិស្ថានសាលារៀនស្អាត និង គុណភាពការរៀន និងបង្រៀននៅកម្រិតបឋមសិក្សា** បានចំនួន២លើក អ្នកចូលរួមសរុប ១៦៦នាក់ (ស្រី១១០នាក់)នៅសាលាបឋមសិក្សាព្រែកជីក និង ចក្រី ដោយបានចូលរួមពីអ្នកផ្តល់សេវាមានឃុំ ការិយាល័យអប់រំ និងសាលារៀន ជាវាគ្មិនតំណាងរដ្ឋ និងប្រជាពលរដ្ឋជាអ្នកមានតម្រូវការសម្រាប់ការសិក្សារបស់កុមារជាពិសេសតម្រូវការតាម **បទដ្ឋានអប្បបរិមាសាលាកុមារមេត្រី** ដែលក្រសួងអប់រំយុវជននិងកីឡា បានចាត់ទុកជាតម្រូវការសម្រាប់ ធានាបានថាកុមារគ្រប់រូបៗទទួល បានសិទ្ធិ និងការអប់រំមានមានគុណភាព។ សវនកម្មសង្គមនេះ បានជួយពង្រឹងដល់ប្រជាពលរដ្ឋ និង សហគមន៍អាចលើកឡើងដោយផ្ទាល់ជាមួយវាគ្មិនពីថ្នាក់ស្រុក-ឃុំ និងការិយាល័យអប់រំ និងគ្រូបង្រៀនជាអ្នកផ្តល់សេវា និងតំណាងមាតបិតាសិស្សជាអ្នកលើកឡើងតម្រូវការ។ កម្មវិធីនេះបានផ្តល់នូវភាព វិជ្ជមានក្នុងការនិយាយត្រង់ៗ និងផ្តល់ការសន្យា និងយោគយល់គ្នាជាជាងការដាក់បន្ទោសនិងតិទៀនគ្នា។

## III- <u>សេចក្តីសន្និដ្ឋានរួម</u>

កុមាររស់នៅតំបន់កំពុងជួបការលំបាក និងជនបទ ព្រៃភ្នំ ផងដែរកុមារពិការ និងងាយរងគ្រោះ មានឱកាសបាន ចូលរៀន ដូចកុមារដទៃទៀត ហើយទន្ទឹមនឹងនេះប្រជាពលរដ្ឋយល់ដឹងកាន់តែប្រសើរឡើងអំពីការគោរពសិទ្ធិកុមារ និងកិច្ចការពារកុមារទាំងអស់គ្នា តាមរយៈ ការចូលរួម និងទទួលបានសិទ្ធិ និងមានការគាំពារ និងផ្តល់សហការគ្រប់ អ្នកពាក់ព័ន្ធទាំងអស់ និងអ្នកទទួលផលទាំងអស់។

ការខិតខំប្រឹងប្រែង និងការអនុវត្តគម្រោង របស់អង្គការខ្មែរដើម្បីការអប់ ដោយកិច្ចសហការល្អ ភាពជាដៃគូជាមួយការិយាល័យពាក់ព័ន្ធនិងមូលដ្ឋាន ឃុំ ស្រុក ខេត្ត គឺឆ្លុះបញ្ចាំងអោយឃើញលទ្ធផលគួរអោយកត់សំគាល់ និងផ្លែផ្កាល្អ ដល់កុមារ និងសហគមន៍របស់គេក្នុងតំបន់នៃ ស្រុករុក្ខគិរី នៅក្នុងឆ្នាំ ២០១៥នេះ។

អង្គការខ្មែរដើម្បីការអប់រំ និងក្រុមការងារពិតជានៅមាន ឆន្ទៈ និងពុះពារបន្តក្នុងបេសកកម្មរបស់ខ្លួន ទៅមុនទៀត ដើម្បី **ឧត្តមប្រយោជន៍កុមារ**កម្ពុជា ជាពិសេសកុមារក្នុងតំបន់ជួបប្រទះការលំបាក និងជនបទ ដោយធ្វើការក្នុងភាពជាដៃគូសហការផ្ទាល់ពីមន្ទីរ/ការិយាល័យជំនាញ អាជ្ញាធរ និងមូលដ្ឋានគ្រប់លំដាប់ និងដោយមានការគាំទ្រពីម្ចាស់មូនីធិនានា នៅពេលខាងមុខបន្តទៀត។

ធ្វើនៅបាត់ដំបង ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៦

**នាយកប្រតិបត្តិ**

**អង្គការខ្មែរដើម្បីការអប់រំ**